# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ៖ ៤០០/២១ អប.សាជលា

# សេចក្តីជូនដំណឹង
## ស្តីពី
## ការថតវីដេអូផ្សាយបន្តផ្ទាល់ក្នុងរមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរាមានកិត្តិយសសូមជូនដំណឹងដល់ភ្ញៀវទេសចរជាតិ-អន្តរជាតិ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា៖ ដើម្បីបញ្ចៀសនូវកំហុសឆ្គងដោយអចេតនា ឬធ្វើឱ្យប៉ះពាល់ដល់គុណតម្លៃរបស់ប្រាសាទខ្មែរដែលជាមរតកមិនអាចកាត់ថ្លៃបានរបស់បុព្វបុរសខ្មែរ និងជាបេតិកភណ្ឌពិភពលោក សូមភ្ញៀវទេសចរជាតិ-អន្តរជាតិ និងសាធារណជនទាំងអស់ដែលមានបំណងចង់ធ្វើការថតវីដេអូផ្សាយបន្តផ្ទាល់ (Live) អំពីប្រវត្តិប្រាសាទនានាក្នុងរមណីយដ្ឋានអង្គរ និងតំបន់ផ្សេងទៀតស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា មេត្តាដាក់សំណើសុំមកអាជ្ញាធរជាតិអប្សរាជាមុន ដោយភ្ជាប់មកជាមួយនូវខ្លឹមសារដែលនឹងត្រូវធ្វើការផ្សព្វផ្សាយផងដែរ។ ចំពោះការស្នើសុំថតផ្សាយបន្តផ្ទាល់អំពីប្រាសាទនានាក្នុងរមណីយដ្ឋានអង្គរដែលមានលក្ខណៈផ្សព្វផ្សាយ ជាសាធារណៈដើម្បីជំរុញវិស័យទេសចរណ៍ គឺពុំតម្រូវឱ្យបង់ប្រាក់នោះទេ លើកលែងតែការស្នើសុំថតលក្ខណៈអាជីវកម្មដែលតម្រូវឱ្យអនុវត្តតាមនីតិវិធី និងគោលការណ៍ដែលបានកំណត់។

អាជ្ញាធរជាតិអប្សរាសូមបញ្ជាក់ជូនថា នាពេលកន្លងមកចាប់តាំងពីមានវត្តមាននៃជំងឺឆ្លងកូវីត-១៩ អាជ្ញាធរជាតិអប្សរាបានអនុញ្ញាតដោយឥតគិតថ្លៃជូនក្រុមហ៊ុន ឬមគ្គុទ្ទេសក៍ទេសចរណ៍ដែលមានអាជ្ញាបណ្ណត្រឹមត្រូវពីក្រសួងទេសចរណ៍ធ្វើការថតឡាយវីដេអូតាមទូរស័ព្ទ ដើម្បីបកស្រាយអំពីប្រវត្តិសាស្រ្តប្រាសាទនានាទៅដល់ភ្ញៀវរបស់ខ្លួនផងដែរ។

ឆ្លៀតក្នុងឱកាសនេះ និងក្នុងគោលដៅដើម្បីអាចគ្រប់គ្រងដោយប្រសិទ្ធភាពនូវការប្រកបអាជីវកម្មការថតសម្លៀកបំពាក់ប្រពៃណីបុរាណ (Pre-Wedding) ក៏ដូចជាជៀសវាងនូវភាពអាណាធិបតេយ្យនានាក្នុងតំបន់រមណីយដ្ឋានអង្គរ អាជ្ញាធរជាតិអប្សរាបានតម្រូវឱ្យសាធារណជនដាក់សំណើសុំការថតសម្លៀកបំពាក់ប្រពៃណីបុរាណ មកអាជ្ញាធរជាតិអប្សរាដើម្បីពិនិត្យ និងផ្តល់ការអនុញ្ញាតជូនដោយឥតបង់ថ្លៃផងដែរ។ តាមរយៈនេះ អាជ្ញាធរជាតិអប្សរាសង្កេតឃើញថា បងប្អូនប្រជាពលរដ្ឋបានចូលរួមអនុវត្តតាមការណែនាំគួរឱ្យកត់សម្គាល់។ សម្រាប់ព័ត៌មានលម្អិត សូមទំនាក់ទំនងមន្ត្រីមជ្ឈមណ្ឌលសេវាកម្មអាជ្ញាធរជាតិអប្សរា តាមរយៈលេខទូរស័ព្ទ ០៦៣៧៦៥៥៧៧ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមភ្ញៀវទេសចរជាតិ-អន្តរជាតិ និងសាធារណជនទាំងអស់មេត្តាជ្រាប និងចូលរួមអនុវត្តតាមការគួរ៕

ថ្ងៃ អង្គារ ០៩ រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

សៀមរាប ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០២១

**អាជ្ញាធរជាតិអប្សរា**


អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្កោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Korng Village, Ampil Commune,
Prasat Bakong District, Siem Reap Province